

# ការណែនាំអំពីលោក ហុង លីម

ខ្ញុំបាទឈ្មោះ ហុង លីម ជាសមាជិកសភាតំបន់ខ្លេយតុន និងជាទីប្រឹក្សា ពិសេសជូន លោករដ្ឋមន្ត្រីទី១ (the Premier) លើផ្នែកទំនាក់ទំនងពាណិជ្ជកម្មរដ្ឋវិចតូរីយ៉ា និងអាស៊ី ។

ខ្ញុំបានមកដល់ប្រទេសអូស្ត្រាលីក្នុងឆ្នាំ ១៩៧០ ក្នុងនាមជា និស្សិតអាហារូប ករណ៍កម្មវិធី កូឡុំបូភ្លែន (Colombo Plan)។ ខ្ញុំបានទទួលសញ្ញាប័ត្រកិត្តិយស ផ្នែកនយោបាយនិង គ្រប់គ្រងពីសាកលវិទ្យាល័យ ថាសមែនា(University of Tasmania)។ បន្ទាប់មកខ្ញុំក៏បានផ្លាស់មកទីក្រុងមែលប៊ិនដើម្បីបន្តការ សិក្សារបស់ខ្ញុំនៅសាកលវិទ្យាល័យមោណាស្ហ (Monash University) ។ ខ្ញុំបានចូលរួមយ៉ាងសកម្មក្នុងកិច្ចការសហគមន៍នៃជនជាតិភាគតិច តាំងពីពេលចូលមកដល់នៃជនភៀសខ្លួនឥណ្ឌូចិនក្នុងប្រទេសអូស្ត្រាលី នៅឆ្នាំ ១៩៧៦ ។ ការចូលរួមទាំងនេះ បាននាំទៅដល់ការគាំទ្រតែងតាំងខ្ញុំបាទជាCommissioner នៃគណៈកម្មការកិច្ចការជនជាតិ ភាគតិចចាប់ពីឆ្នាំ ១៩៨៥ ដល់ឆ្នាំ ១៩៩៣ ។ នៅឆ្នាំ ១៩៧៧ ខ្ញុំបានចាប់ផ្តើមការងាររយៈពេល ១៦ឆ្នាំ ក្នុងការងារបម្រើសាធារណៈជនក្នុងរដ្ឋវិចតូរីយ៉ា ដោយធ្វើការងារក្នុងផ្នែកអភិវឌ្ឍន៍ធនធានមនុស្ស និងកម្មវិធីទីផ្សារការងារ ក្នុងក្រសួង ស្ថាប័នផ្សេងៗរបស់រដ្ឋ ។ ក្នុងឆ្នាំ ១៩៩៣ ខ្ញុំបានលាលែងឈប់ពីការងារទាំងនេះហើយទៅបម្រើការងារជាទីប្រឹក្សាផ្នែកការងារជូនយុវជន ជាមួយសមាគមខ្មែរ រហូតដល់ពេលជាប់ឆ្នោតជាសមាជិកសភារដ្ឋវិចតូរីយ៉ា នាខែមិនា ឆ្នាំ ១៩៩៦។